## គោលការណ៍សមាមាត្រ (proportionality)

គោលការណ៍បែងចែក (principle of distinction) មិនបានគ្របដល់ការខូចខាត ដែលមិនមានចេតនា កើតពីការវាយប្រហារលើគោលដៅយោធា (military objective)។

ច្បាប់មនុស្សធម៌អន្តរជាតិ ហាមឃាត់ការវាយប្រហារ ដែលអាចនាំទូវការបាត់បងជីវិតជនស៊ីវិល ទ្រព្យសម្បត្តិដោយចៃដន្យ ដែលរួមផ្សំគ្នា អាចហួសពីភាពចាំបាច់នៃគោលបំណងយោធាផ្ទាល់ដែលត្រូវបានរំពឹងទុក (Optional Protocol I to Geneva Convention, មាត្រា ៥១.៥(ខ))។

គោលការណ៍សមាមាត្រ ជាចម្បងទាក់ទងនឹងមធ្យោបាយនៃការវាយប្រហារ និងពាក់ព័ន្ធនឹងការបកស្រាយពាក្យ "គោលបំណង ឬផលប្រយោជន៍យោធាផ្ទាល់"។ ផលប្រយោជន៍ ត្រូវតែជាប្រភេទយោធា និងឈរក្នុងទីតាំងសម្រាប់នាំឲ្យឈានទៅមុខ ឬចុះខ្សោយកម្លាំងទ័ព។ ពាក្យនេះ សំដៅដល់ផលប្រយោជន៍យោធា ដែលអាចប្រមើលមើល ដោយចារីក្នុងពេលវេលាប្រព្រឹត្តនោះ។ ការទាមទារនូវភាពអាចប្រមើលមើល មានភាពចាំបាច់ ដោយសារ វាបានបដិសេធនូវការពឹងផ្អែកលើយុត្តិកម្មតុល្លាភាព (ដោយប្រយោបល) (de facto justification)។ ផលប្រយោជន៍ផ្ទាល់នេះ គឺជាផលប្រយោជន៍ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធ និង substantial។ ជាចុងក្រោយ មិនមាន រូបមន្តសម្រាប់ថ្លឹង រវាងការបាត់បង់ជីវិត និង ផលប្រយោជន៍យោធាផ្ទាល់ ដែលគេរំពឹងនោះទេ។

ការបំពានគោលការណ៍សមាមាត្រា អាចជាការបំពានធ្ងន់ធ្ងរ (grave breaches) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 469-471)។